**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-Dec-2011, 12:39
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ: **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ការជំទាស់របស់លោក អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួនរបស់ ក.ស.ព សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តី៖**
អាង ឧត្តម
Michael G. KARNAVAS

ផ្ញើជូន៖

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **យ៉ូរ ឧត្តរា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew T. CAYLEY

**ក្រុមមេធាវីជនជាប់ចោទទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់គាត់ (“មេធាវីការពារក្ដី”) អនុលោមតាមវិធាន ៨៤(១) និងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង សូមដាក់ការជំទាស់របស់ខ្លួន ដូចមានភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធ ស្រាប់ ទៅនឹងការទទួលឯកសារមួយចំនួនរបស់ ក.ស.ព សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ៥ ខែ ធ្នូ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)។ ការជំទាស់ទាំងនេះត្រូវបានដាក់ ទោះបីតាមពិត មេធាវីការពារក្ដីបានអនុវត្តតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងឯកសារសម្រាប់សវនាការដំណាក់កាលដំបូង ដែលបានចែងថា ភាគីអាចជំទាស់ទៅនឹងឯកសារតាមប្រភេទ[១]។ ការជំទាស់ទាំងនេះត្រូវបានដាក់ដើម្បីជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចពីភាពអាចទទួលយកបានជាភស្តុតាងនៃឯកសារជាក់លាក់នៅចំពោះមុខអង្គជំនុំជម្រះនេះក្នុងសំណុំរឿង ០០២/០១ និងដើម្បីបង្កើនភាពច្បាស់លាស់ និងភាពប្រាកដប្រជា ទាក់ទិននឹងគោលជំហររបស់មេធាវីការពារក្ដីទាក់ទងនឹងឯកសារនីមួយៗ។ ការជំទាស់ទាំងនេះត្រូវបានដាក់ ដោយយល់ថា មេធាវីការពារពុំអាចវាយតម្លៃពីយថាភាពនៃឯកសារទាំងនោះបាន។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមជំទាស់ទៅនឹងការទទួលទទួលឯកសារណាដែលមិនមានយថាភាពច្បាស់លាស់ ឬភាគីដែលបានដាក់ឯកសារនោះមិនបានបង្ហាញពីយថាភាពរបស់វា។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយនេះ មេធាវីការពារក្ដីសូមស្នើដោយក្ដីគោរពដល់អង្គជំនុំជម្រះសាលដំបូងសូមមេត្តា**បដិសេធ**ឯកសារនានាដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយ។

---

[១] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាសម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E131/1, ទំព័រ ២។ *សូមមើលផងដែរ* ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន,ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E114; សំណើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ, ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E33; សារណារបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់សម្ភារៈទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E59; ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E96/3។

សូមដាក់ជូនដោយក្ដីគោរព

| | |
|---|---|
| អាង ឧត្ដម | Michael G. KARNAVAS |

សហមេធាវីការពារលោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១